**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្ដីការគណៈរដ្ឋមន្ត្រី**
**អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល**
**លេខ: ១០៩/២៣ អអរ**

# សេចក្ដីប្រកាសព័ត៌មាន
## លទ្ធផលនៃសន្និសីទសារព័ត៌មានស្ដីពី "ភាពជោគជ័យក្នុងរយៈពេល ៥ឆ្នាំកន្លងមក របស់រដ្ឋបាលខេត្តព្រៃវែង"

នាព្រឹកថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៣ អង្គភាពអ្នកនាំពាក្យរដ្ឋាភិបាលបានរៀបចំសន្និសីទសារព័ត៌មាន ស្ដីពី **«ភាពជោគជ័យក្នុងរយៈពេល ៥ឆ្នាំកន្លងមក របស់រដ្ឋបាលខេត្តព្រៃវែង»** ដែលមានវាគ្មិនចូលរួមគឺ៖

- **ឯកឧត្តម ជា សុមេធី អភិបាលនៃគណៈអភិបាលខេត្តព្រៃវែង**
- **មន្ទីរអង្គភាពជំនាញជុំវិញរដ្ឋបាលខេត្តព្រៃវែង**

ខ្លឹមសារនៃសន្និសីទសារព័ត៌មាន មានគោលបំណងពន្យល់ និងផ្សព្វផ្សាយដល់សាធារណជនឱ្យបានជ្រាបច្បាស់អំពី យន្តការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងភាពជោគជ័យដែលរដ្ឋបាលខេត្តព្រៃវែង ខិតខំប្រឹងប្រែងអនុវត្ត ព្រមទាំងសម្រេចបានសមិទ្ធផលវិជ្ជមាន ក្រោមការដឹកនាំដ៏ប៉ិនប្រសប់ប្រកបដោយថាមពលរបស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។**

## I. ស្ថានភាពទូទៅ

ខេត្តព្រៃវែង បែងចែកចេញជា ក្រុង១ ស្រុក១២ ឃុំ១១២ សង្កាត់៤ និងភូមិចំនួន ១.១៦៨ ដែលមានប្រជាពលរដ្ឋរស់នៅចំនួន ១.២៦៣.១៨២នាក់ ស្មើនឹង ២៩៥.០៧៤គ្រួសារ។ សេដ្ឋកិច្ចខេត្តមានទំហំប្រមាណ ១.៧៣៨លានដុល្លាអាមេរិក ស្មើនឹង ៣,៨% នៃសេដ្ឋកិច្ចជាតិ មានការកើនឡើង ៣៦% បើធៀបនឹងឆ្នាំ២០១៨ ហើយចំណូលជាមធ្យមសម្រាប់មនុស្សម្នាក់ៗមានចំនួន ១.៣០៣ ដុល្លារអាមេរិក។

## II. សមិទ្ធផលការងារ

ក្នុងរយៈពេល ៥ឆ្នាំកន្លងមកនេះ(២០១៨-២០២២) សមិទ្ធផលការងារសំខាន់ៗ ដែលសម្រេចបានរួមមាន៖

- **វិស័យគាំពារសង្គម៖** រដ្ឋបាលខេត្ត បានអនុវត្តនូវគោលនយោបាយគាំពារសង្គមរបស់រាជរដ្ឋាភិបាល ដោយឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ចំនួន ៧៦.៧៨១គ្រួសារ ទឹកប្រាក់សរុប ២៨០.០៩៥លានរៀល, ស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ ចំនួន ១០.៣១១នាក់ ចំណាយទឹកប្រាក់សរុប ៤.៥០២លានរៀល, ឧបត្ថម្ភជូនគ្រួសារងាយរងហានិភ័យ ក្នុងអំឡុងពេលមានសម្ពាធអតិផរណាចំនួន ១១.៣៦០ គ្រួសារ សរុបថវិកាចំនួន ១.៣៥៩លានរៀល និងគ្រោះទឹកជំនន់ចំនួន ៣.៨៦៩គ្រួសារ ចំណាយទឹកប្រាក់ ៥៧៦លានរៀល។
- **វិស័យកសិកម្ម៖** ការងារកសិកម្មទូទាំងខេត្ត មានការរីកចម្រើនគួរកត់សម្គាល់ ដោយខេត្តមានផ្ទៃដីដាំដុះសរុប ៣៣៧.០០០ហិកតា ក្នុងនោះទទួលបានផលទៅលើដំណាំស្រូវជាមធ្យម ១លានតោន ក្នុងមួយឆ្នាំ ដែលបានជាប់ចំណាត់ថ្នាក់លេខមួយ លើការផលិតស្រូវ។ ខេត្តបានជំរុញនូវការបង្កើតជាសហគមន៍កសិកម្ម ក្នុងន័យបង្កើននូវទិន្នផលកសិកម្មបន្ថែមទាំងទៅលើដំណាំ បន្លែ ក៏ដូចជាការចិញ្ចឹមសត្វជាដើម។ ជាមួយគ្នានេះ ការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រត្រូវបានយកចិត្តទុកដាក់ ដោយបច្ចុប្បន្ននេះ មានចំនួន ១៧៧កន្លែង មានលទ្ធភាពស្រោចស្រពបានចំនួន ១៣៧.៣៣៤ហិកតា។
- **ការផ្តល់សេវាសាធារណៈ៖** រដ្ឋបាលខេត្ត បានជំរុញនូវការផ្តល់សេវាសាធារណៈ តាមរយៈយន្តការច្រកចេញ-ចូលតែមួយ ដោយអង្គភាពច្រកចេញ-ចូលតែមួយខេត្ត ផ្តល់សេវាលើ ១៤វិស័យ ការិយាល័យច្រកចេញ-ចូលតែមួយក្រុង ស្រុក ផ្តល់លើ១៣វិស័យ ព្រមទាំងបានពង្រីកនូវយន្តការនេះ ដល់មូលដ្ឋានឃុំ-សង្កាត់ទាំង ១១៦ឃុំ-សង្កាត់ទូទាំងខេត្ត។ យន្តការនេះ បានផ្តល់ដល់ប្រជាពលរដ្ឋសរុប ៨៦.៦៤៣សេវា ទទួលបានចំណូលសរុប ២,០២លានដុល្លាអាមេរិក។
- **វិស័យអប់រំ៖** ការងារអប់រំ បណ្តុះបណ្តាល និងអភិវឌ្ឍន៍ធនធានមនុស្សត្រូវបានយកចិត្តទុកដាក់ តាមរយៈការពង្រីកការសាងសង់សាលារៀនជាបន្តបន្ទាប់ ពិសេសនៅតាមទីជនបទ និងតំបន់ដាច់ស្រយាល ដោយទូទាំងខេត្ត មានសាលាមត្តេយ្យ ៧០៨កន្លែង បឋមសិក្សា ៥៤៧កន្លែង អនុវិទ្យាល័យ ៩៣កន្លែង វិទ្យាល័យ ៣៣កន្លែង វិទ្យាស្ថាន ២កន្លែង សាកលវិទ្យាល័យ ២កន្លែង សាលាបណ្តុះបណ្តាល ២កន្លែង និងមជ្ឈមណ្ឌលសិក្សាសហគមន៍ ១៤កន្លែង។ ក្នុងរយៈពេល ៥ឆ្នាំកន្លងមក ខេត្តមានសិស្សប្រលងជាប់មធ្យមសិក្សាទុតិយភូមិចំនួន ៨៤,៥៥% ក្នុងនោះ និទ្ទេសA ចំនួន ១៨៥នាក់។

- **ការងារសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ៖** ដោយមានការចូលរួមពីកងកម្លាំងគ្រប់លំដាប់ថ្នាក់ និងប្រជាពលរដ្ឋទាំងអស់ ទូទាំងខេត្តរក្សាបាននូវសន្តិសុខសណ្តាប់ធ្នាប់ល្អប្រសើរ ការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ទទួលបានលទ្ធផលល្អ ដោយបានជាប់ចំណាត់ថ្នាក់លេខ១ ចំនួន ៨៥ឃុំ-សង្កាត់ ក្នុងចលនាប្រលងប្រណាំងភូមិ-ឃុំមានសុវត្ថិភាពនេះ។ ដោយឡែកបទល្មើស ក៏ត្រូវបានបង្ក្រាបជាបន្តបន្ទាប់។
- **ការងារអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត៖** រដ្ឋបាលខេត្ត បានយកចិត្តទុកដាក់ក្នុងការអភិវឌ្ឍនូវវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត សំដៅតភ្ជាប់បណ្តាញផ្លូវពីក្រុង ស្រុក ទៅកាន់ឃុំ សង្កាត់ ពីតំបន់ដាច់ស្រយាល ទៅកាន់ទីប្រជុំជន។ ចំពោះការងារផ្គត់ផ្គង់អគ្គិសនី ទឹកស្អាត និងអនាម័យជនបទត្រូវបានលើកកម្ពស់ ដោយប្រជាពលរដ្ឋទទួលបានអគ្គិសនីប្រើប្រាស់ចំនួន ៩០,៣% ទឹកស្អាតចំនួន ៩២% និងអត្រាគ្របដណ្តប់នៃអ្នកមានបង្គន់អនាម័យប្រើប្រាស់ ១០០% ព្រមទាំងបានបញ្ចប់នូវការបន្ទោបង់ពាសវាលពាសកាល (ODF)ផងដែរ។

## III. ទិសដៅការងារបន្ត

រដ្ឋបាលខេត្តព្រៃវែង បានដាក់ចេញនូវទិសដៅការងារសំខាន់ៗ ដែលរួមមាន៖

- ខិតខំអនុវត្តកម្មវិធីនយោបាយ យុទ្ធសាស្រ្តចតុកោណ ផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគ របស់រាជរដ្ឋាភិបាល ឱ្យកាន់តែទទួលបាននូវជោគជ័យបន្ថែម
- ប្តេជ្ញារក្សាសន្តិភាព សណ្តាប់ធ្នាប់សាធារណៈ តាមរយៈការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព និងបទបញ្ជារាជរដ្ឋាភិបាលឱ្យកាន់តែមានប្រសិទ្ធភាព
- បន្តជំរុញការកសាងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ទីប្រជុំជន និងជនបទ តាមសំណូមពរចាំបាច់របស់ប្រជាពលរដ្ឋមូលដ្ឋាន
- បង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ដោះស្រាយសំណើរ សំណូមពរ បញ្ហាប្រឈម និងតម្រូវការប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ
- ទាក់ទាញវិនិយោគិនបន្ថែម ដើម្បីចូលរួមចំណែកអភិវឌ្ឍន៍ខេត្ត ឱ្យកាន់តែមានសន្ទុះរីកចម្រើនខ្លាំងឡើង៕

ថ្ងៃពុធ ១កើត ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៣